**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ [illegible]

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៣៨ នៃប្រតិបត្តិការធនាគារកណ្តាល
## ១០ តុលា ១៩៧៩ - ១០ តុលា ២០១៧
**រាជធានីភ្នំពេញ ថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៧**

ធនាគារជាតិនៃកម្ពុជា បានប្រារព្ធពិធីរំឭកខួបអនុស្សាវរីយ៍លើកទី៣៨ នៃការបង្កើតធនាគារ-ជាតិនៃកម្ពុជាឡើងវិញ ១០ តុលា ១៩៧៩ - ១០ តុលា ២០១៧ ក្រោមអធិបតីភាពឯកឧត្តម ជា ចាន់ តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា។ ពិធីនេះ មានការអញ្ជើញចូលរួមពីសំណាក់មន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជាទាំងស្នាក់ការកណ្តាលនិងសាខារាជធានី-ខេត្ត ព្រមទាំងនិស្សិត សរុបប្រមាណ ៩០០ នាក់។

ពិធីនេះ មានគោលបំណងរំឭកខួបអនុស្សាវរីយ៍នៃការបង្កើតធនាគារជាតិនៃកម្ពុជាឡើងវិញ និងអបអរសាទរចំពោះសមិទ្ធផលដែលប្រព័ន្ធធនាគារសម្រេចបាន ក្នុងរយៈពេល៣៨ឆ្នាំ កន្លងមក។ នាឱកាសនោះ ឯកឧត្តម ទេសាភិបាល បានបង្ហាញពីដំណើរដ៏វែងឆ្ងាយពីការអភិវឌ្ឍប្រព័ន្ធធនាគារ និងរូបិយវត្ថុនៅអតីតកាល នាពេលបច្ចុប្បន្ន និងផែនការយុទ្ធសាស្ត្រនាពេលអនាគត។ ម្យ៉ាងទៀត ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ក៏បានធ្វើបទអន្តាគមន៍លើប្រធានបទពាក់ព័ន្ធនិងតួនាទីរូបិយវត្ថុ ការអភិវឌ្ឍសេដ្ឋកិច្ច ព្រមទាំងតម្លៃនៃសន្តិភាពដែលបានអភិវឌ្ឍសេដ្ឋកិច្ចនិងវិស័យហិរញ្ញវត្ថុយ៉ាងឆាប់រហ័ស។

គួររំឭកឡើងវិញថា ក្រោយថ្ងៃមហាជ័យជម្នះ ៧ មករា ឆ្នាំ១៩៧៩ ការបង្កើតធនាគារកណ្តាលឡើងវិញ គឺចាប់ផ្តើមពីបាតដៃទទេ ប៉ុន្តែរហូតមកដល់បច្ចុប្បន្ន ប្រព័ន្ធធនាគារបានបោះជំហានទៅមុខយ៉ាងរឹងមាំទាំងផ្នែករូបវន្តនិងគុណភាព។ ជាក់ស្តែង រាជរដ្ឋាភិបាលបានចាត់ទុកប្រព័ន្ធធនាគារបានដើរតួនាទីស្នូលក្នុងការគាំទ្រកំណើនសេដ្ឋកិច្ច ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កាត់បន្ថយភាពក្រីក្រ និងជំរុញសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងតំបន់និងពិភពលោក។ ទន្ទឹមនេះ តាមការវាយតម្លៃរបស់មជ្ឈដ្ឋានអន្តរជាតិ ដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារពិភពលោក និងភ្នាក់ងារចំណាត់ថ្នាក់ Moody's បានបង្ហាញថា ប្រព័ន្ធធនាគារកម្ពុជាទទួលបានជំនឿទុកចិត្តខ្ពស់ពីវិស័យឯកជន និងជាប់ចំណាត់ថ្នាក់ទី៧លើភាពងាយស្រួលទទួលបានសេវាហិរញ្ញវត្ថុ ហើយនារយៈពេលកន្លងមក ធនាគារជាតិនៃកម្ពុជាជាប់ចំណាត់ថ្នាក់ល្អក្នុងការរួមចំណែករក្សាស្ថិរភាពសេដ្ឋកិច្ចនិងអត្រាប្តូរប្រាក់ ដែលគាំទ្រដល់លំហូរចូលនៃវិនិយោគផ្ទាល់បរទេសមកកម្ពុជា ទោះបីជាស្ថិតក្រោមកម្រិតដុល្លាររូបនីយកម្មខ្ពស់ក៏ដោយ។

**ទំនាក់ទំនង៖**
ផ្នែកទំនាក់ទំនង, ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ៖ (៨៥៥) ២៣ ៩៩០ ១៩៦
អ៊ីម៉ែល៖ nbccommunication@nbc.org.kh